# អតីតកងការពារផ្តល់សក្ខីកម្មដ៏ពិស្តារទាក់ទងនឹងប្រតិបត្តិការក្នុងគុក ប៉ុន្តែតុលាការបង្ហាញពីការព្រួយបារម្ភអំពីភាពដែលអាចជឿបានរបស់អតីតកងការពារនេះ

ឆាល ដែកសាន់

អតីតកងការពារគុក ប្រាក់ ខន ត្រូវបានណែនាំខ្លួនថាជាសាក្សីបន្តរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ថ្ងៃនេះនៅក្នុងតុលាការកាត់ទោសប្រធានគុក កាំង ហ្គេចអ៊ាវ (ហៅ ឌុច) ។ តាមរយៈសំណួរពីចៅក្រម យ៉ា សុខន, ស៊ីលវៀ ខាតវ៉្រាយត៍ និងចៅក្រម ហ្សង់ម៉ាក ឡាវែញ អង្គជំនុំជម្រះសាលាដំបូង បានត្រួតពិនិត្យលើព័ត៌មាននៃការចូលរួមសកម្មភាពរបស់ ប្រាក់ ខន ជាមួយនឹងខ្មែរក្រហមចាប់តាំងពីពេលដែល ប្រាក់ ខន បានចូលបំរើបដិវត្តន៍ រហូតដល់ថ្ងៃរំដោះរបស់វៀតណាមនៅឆ្នាំ១៩៧៩ ។

ប្រាក់ ខន អាយុ៥៧ ដំបូងឡើយបានចូលក្នុងផ្នែកកសិកម្មនៅស្រុក៥៦ តាខ្មៅ ឆ្នាំ១៩៧២ ។ មួយរយៈខ្លីក្រោយមក ប្រាក់ ខន ត្រូវបានបញ្ជូនទៅកងយោធា ហើយផ្លាស់ទៅព្រៃសជាកន្លែងដែល ប្រាក់ ខន បានជួយលើកទំនប់ទឹក ជីកប្រឡាយ និងធ្វើស្រែ ។ ពីរបីខែក្រោយមក ប្រាក់ ខន ក៏ត្រូវបានបញ្ជូនទៅកន្លែងថ្មីម្តងទៀតដែលលើកនេះមកធ្វើជាកងការពារមន្ទីរស-២១ ដែលត្រូវបានស្គាល់ថា គុកទួលស្លែង ។

ពេលមកដល់មន្ទីរស-២១ ប្រាក់ ខន ត្រូវបានដាក់ឲ្យនៅជាមួយក្រុមមួយដែលមានអ្នកយាមការពារប្រដាប់ដោយអាវុធពី១០ទៅ១២នាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហ៊ឹម ហ៊ុយ និងសមមិត្ត ហ៊ី ។ ក្រុមរបស់ ប្រាក់ ខន ទទួលខុសត្រូវលើការត្រួតពិនិត្យរាល់ការចេញចូលក្នុងបរិវេណគុក ។ ខណៈពេលដែលធ្វើការរយៈពេល១២ម៉ោង ក្បែរមាត់របងគុកដើម្បីបញ្ជូនអ្នកទោសចូលក្នុងបរិវេណគុក ប្រាក់ ខន បានផ្តល់សក្ខីកម្មថា គាត់បានឃើញឡានដឹកជនរងគ្រោះត្រូវបានបើកចូលក្នុងគុក ។ សម្រាប់ឡានធំៗមានដឹកមនុស្សពី២០ទៅ៣០នាក់ ចំណែកឡានតូចៗមានដឹកមនុស្សប្រហែល១០នាក់ ។ ចំណែក«ខ្មាំង» ត្រូវបាននាំមកជាមួយនឹងសមាជិកគ្រួសារគេ ដូច្នេះឡានភាគច្រើនមានដឹកបុរស ស្ត្រី និងក្មេងៗ ។ អ្នកទោសខ្លះបានជាប់ខ្នោះ ហើយត្រូវបាននាំចូលក្នុងគុកភ្លាមតែម្តង ខណៈពេលដែលអ្នកទោសដទៃទៀត មិនត្រូវបានចាប់ខ្លួនឲ្យត្រឹមត្រូវនៅឡើយទេ ។ អ្នកទោសដែលមិនត្រូវបានចាប់ខ្លួនត្រឹមត្រូវទាំងអស់នេះត្រូវបានបញ្ជូនទៅកាន់ផ្ទះមួយដែលមាន ហ៊ឹម ហ៊ុយ និងកងការពារដែលនៅក្រោមបញ្ជារបស់ ហ៊ឹម ហ៊ុយ ធ្វើការចាប់ខ្លួនដាក់ខ្នោះ និងចង់បិទមុខអ្នកទោសទាំងនោះ បន្ទាប់មកបញ្ជូនដាក់លើឡានវិញ និងនាំចូលទៅក្នុងគុក ។ ជាមួយគ្នានេះ ប្រាក់ ខន ក៏បាន

និយាយថា គាត់បានឃើញឡានដឹកអ្នកទោសពេញៗ ធ្វើដំណើរចេញពីគុកក្នុងចំនួនប្រហាក់ប្រហែលនឹងអ្នកទោសដែលដឹកចូលគុកដែរ។ ប្រតិបត្តិការបែបនេះបានផ្ដល់នូវចំណាប់អារម្មណ៍មួយថា មន្ទីរ ស-២១ បានប្រតិបត្តិការផ្សេងតាមរបៀបជាខ្សែសង្វាក់ដ៏មានប្រសិទ្ធិភាព។

ប្រាក់ ខន បានបន្តពិភាក្សាទៅលើទិដ្ឋភាពផ្នែករដ្ឋបាលនៃការឃុំខ្លួនអ្នកទោស។ ក្រោយពីចាប់ខ្លួនហើយ អ្នកទោសត្រូវបានបែងចែកជាផ្នែកដោយ ឌុច ដោយយោងទៅតាមអំណាចរបស់គាត់។ អ្នកទោសធម្មតាត្រូវបានឃុំក្នុងគុកទួលស្លែង ចំណែកឯអ្នកទោស "សំខាន់" ត្រូវបានឃុំក្នុងគុក "ពិសេស" មួយដែលស្ថិតនៅក្រៅបរិវេណគុកទួលស្លែង។ ពេលមកដល់គុក អ្នកទោសដែលមកជាគ្រួសារត្រូវបានបំបែកចេញពីគ្នា។ បុរស និងស្ត្រី ត្រូវបានឃុំខ្លួននៅក្នុងអគារខុសគ្នា ចំណែកក្មេងៗត្រូវបានយកទៅសម្លាប់ភ្លាមៗតែម្ដង។ ប្រាក់ ខន បាននិយាយថា មានពេលមួយនោះ ប្រធានរបស់គាត់បានយកក្មេងដែលមានអាយុប្រហែល៧-៨ខែ ចេញពីដៃម្ដាយក្មេងនោះ ហើយបោះក្មេងនោះទម្លាក់ពីគុកនៅជាន់លើដែលធ្វើឲ្យក្មេងនោះស្លាប់បាត់ទៅ។ បន្ទាប់មក ប្រាក់ ខន ត្រូវបានបញ្ជាឲ្យយកក្មេងនោះទៅកប់។

នៅចុងឆ្នាំ១៩៧៦ ក្រោយពីបានធ្វើការជាកងការពារនៅខាងក្រៅគុកទួលស្លែងមក ប្រាក់ ខន ត្រូវបានបញ្ជូនមកកងសួរចម្លើយរបស់មន្ទីរស-២១។ ដោយធ្វើការពិភាក្សាលើវិធីសាស្ត្រដែលខ្លួនបានរៀនពីរបៀបបំពេញតួនាទីថ្មីនោះ ប្រាក់ ខន បាននិយាយថា គ្មានថ្នាក់រៀនឬមេរៀនត្រឹមត្រូវស្ដីពីការសួរចម្លើយឡើយនៅពេលដែលគាត់ចាប់ផ្ដើមការងារ។ ប៉ុន្តែ អ្នកដែលត្រូវជ្រើសតាំងថ្មីទាំងអស់នេះ ត្រូវបានចាត់ឲ្យទៅជាមួយអ្នកសួរចម្លើយជំនាញដើម្បីហាត់រៀនរយៈពេលពីរ-បីខែដោយធ្វើការសង្កេត និងរៀនពីរបៀបទាញយកចម្លើយសារភាពពីអ្នកទោស។ យ៉ាងណាមិញ មួយរយៈពេលក្រោយមក ប្រាក់ ខន បាននិយាយថា ឌុច ចាប់ផ្ដើមការបង្រៀនវគ្គសិក្សានៅ "សាលានយោបាយ" ជាកន្លែងដែលគាត់បានបង្រៀនអ្នកសួរចម្លើយពីមនោគមវិជ្ជានយោបាយ វិធីសាស្ត្រសួរចម្លើយ និងការធ្វើទារុណកម្មមិនឲ្យស្លាប់ រួមមាន ការឆក់ខ្សែភ្លើង ការចាក់ម្ជុលចូលក្នុងក្រចកដៃវាយនឹងរំពាត់ និង វាយដំទាត់ធាក់។ ប្រាក់ ខន ក៏បាននិយាយថា ឌុច បានបង្រៀនពីវិធីសាស្ត្រនៃការប្រមាថមាក់ងាយ ដោយបង្គាប់ឲ្យអ្នកសួរចម្លើយបង្ខំឲ្យអ្នកទោស ស៊ីលាមកខ្លួនឯង និងលាមកសត្វឆ្កែ។

ក្រោយមកទៀត ប្រាក់ ខន បានឆ្លើយនឹងសំណួរទាក់ទងនឹងសេចក្ដីលម្អិតនៃវិជ្ជាដឹកនាំក្នុងការអនុវត្តការសួរចម្លើយ។ ប្រាក់ ខន បានពន្យល់ថា កងសួរចម្លើយដែលដឹកនាំដោយ ឌុច និងអ្នកដឹកនាំទីពីរគឺ បង ហ៊ ត្រូវបានបំបែកចេញជាបីក្រុមៈ ក្រុមត្រជាក់ ក្រុមក្ដៅ និងក្រុមអង្គាម។ ក្រុម

ត្រដាក់ យកចិត្តទុកដាក់លើអ្នកទោសដែលពិចារណាមើលទៅដូចជាមិនសូវសំខាន់ប៉ុន្មានទេ ហើយនិង គ្រាន់តែអនុវត្តសួរសំណួរទាក់ទងនឹងការដាក់សម្ពាធលើផ្នែកនយោបាយតែប៉ុណ្ណោះ។ ចំណែកឯ ក្រុមក្ដៅវិញ បានធ្វើទារុណ្ណកម្ម ដើម្បីទាញយកចម្លើយសារភាពពីអ្នកទោសទាំងនោះ ដែលពិចារណាមើលទៅដូចជាមានព័ត៌មានសំខាន់ជាង។ ប្រសិនបើក្រោយពីត្រូវបានសួរសំណួរដោយក្រុមក្ដៅហើយ អ្នកទោសនៅតែមិនបានផ្ដល់ចម្លើយសារភាពទេនោះ ក្រុមអន្ទាមដែលមាន ប្រាក់ ខន ជាសមាជិក នឹងត្រូវបានបញ្ជាឲ្យអនុវត្តវិធីសាស្ត្រធ្វើទារុណ្ណកម្ម និងធ្វើការប្រមាថមាក់ងាយដើម្បីសម្រេចនូវកាតព្វកិច្ចនេះ។

សម្រាប់ការសួរចម្លើយពិសេសណាមួយ ប្រាក់ ខន បាននិយាយថា ដំបូង ប្រាក់ ខន នឹងទទួលបញ្ជាពី ឌុច តាមរយៈទូរស័ព្ទ ឬសារសរសេរដោយដៃដែលបង្គាប់ឲ្យ ប្រាក់ ខន សួរចម្លើយអ្នកទោសណាម្នាក់។ បន្ទាប់មក ប្រាក់ ខន នឹងស៊ើបរកមើលព័ត៌មានថាតើអ្នកទោសរូបនោះត្រូវបានឃុំឃាំងនៅកន្លែងណា ហើយធ្វើការស្នើសុំដើម្បីនាំអ្នកទោសនោះមកឲ្យគាត់ និងពេលមកដល់ក៏បណ្ដើរអ្នកទោសចូលទៅក្នុងបន្ទប់សួរចម្លើយ។ ក្រោយមក អ្នកទោសនឹងត្រូវបានបញ្ជូនទៅកាន់គុករបស់គេវិញរហូតដល់ថ្ងៃបន្ទាប់ពេលដែលការសួរចម្លើយចាប់ផ្ដើមធ្វើបន្តទៀត។

ជាមួយគ្នានេះ ប្រាក់ ខន ក៏បានរៀបរាប់ពីស្ថានភាពគុកទូទៅនៅក្នុងមន្ទីរស-២១ ដែលបានផ្ដល់ឲ្យនូវសេចក្ដីលម្អិតប្រហាក់ប្រហែល ឬដូចគ្នានឹងសាក្សីដទៃទៀត។ ខណៈពេលដែលមិនបានឃើញពីស្ថានភាព “គុកពិសេស” ប្រាក់ ខន បាននិយាយថា អ្នកទោសមួយភាគធំត្រូវបានដាក់ឃុំក្នុងគុកសម្រាប់ឃុំអ្នកទោសតែម្នាក់ និង បន្ទប់សម្រាប់ឃុំអ្នកទោសរួមតាមអគារ B, C, និង D ក្នុងរបងគុកទួលស្លែង។ គុកសម្រាប់ឃុំអ្នកទោសតែម្នាក់ ត្រូវបានប្រើសម្រាប់អ្នកទោសដែលត្រូវបានសួរចម្លើយជាញឹកញាប់ ចំណែកឯបន្ទប់សម្រាប់ឃុំអ្នកទោសរួមត្រូវបានប្រើជាផ្ទះឃុំឃាំង។ មនុស្សវិកលចរិកត្រូវបានឃុំខ្លួននៅក្នុងគុកសម្រាប់អ្នកទោសតែម្នាក់។ បុរស និងស្ត្រីត្រូវបានឃុំនៅក្នុងបន្ទប់ដាច់ដោយឡែកផ្សេងគ្នា និងដែលស្ថិតនៅក្នុងស្ថានភាពផ្សេងគ្នាផងដែរ។ ប្រាក់ ខន បានរៀបរាប់ពីបន្ទប់ឃុំអ្នកទោសរួមដូច្នេះថា បន្ទប់នីមួយៗមានអ្នកទោសពីរជួរដែលក្នុងមួយជួរមាន៩នាក់ដេកលើឥដ្ឋការ៉ូ ហើយជើងត្រូវជាប់ខ្នោះនឹងរនងដែកវែង ចំណែកស្ត្រីវិញមិនត្រូវបានជាប់ខ្នោះ ហើយអាចធ្វើចលនាបាននៅក្នុងបន្ទប់ដោយទ្វារបន្ទប់នោះបានចាក់សោរជាប់ពីខាងក្រៅ។

សម្រាប់តម្រូវការមូលដ្ឋានចាំបាច់វិញ អ្នកទោសត្រូវបានទទួលរបបបបរដ៏តិចតួច និងកេះដាក់គ្រាប់ទទេមួយសម្រាប់បន្ទោបង់ ហើយត្រូវបានយកទៅសម្អាតដោយអ្នកយាមរៀងរាល់ពីរ-បីថ្ងៃម្ដង។

ទោះបីជាសាក្សីបានចំណាយពេលយ៉ាងច្រើននៅពេលព្រឹកនេះ ដោយបានផ្ដល់នូវសេចក្ដីលម្អិតដែលផ្ដល់ភស្ដុតាងតាមរយៈសក្ខីកម្មពីអតីតកាលនៅចំពោះមុខតុលាការយ៉ាងណាក្ដី ក៏ក្រោយពីពាក់កណ្ដាលថ្ងៃនៃដំណើរការនេះ ទាំងចៅក្រម ស៊ីវៀលខាតវ៉្រាយ និងចៅក្រម ហ្វង់ ម៉ាក់ឡាវីញ បានបញ្ចេញនូវការងឹងឆ្ងល់គួរឲ្យកត់សម្គាល់ទាក់ទងនឹងភាពដែលអាចជឿបានរបស់សាក្សី ។ ដោយបានបង្ហាញឲ្យឃើញពីភាពផ្ទុយគ្នា និងភាពមិនស៊ីចង្វាក់គ្នាដែលនិយាយដោយសាក្សី អ្នកស្រីចៅក្រម ខាត់វ៉្រាយ បានកត់សម្គាល់ថា ប្រាក់ ខន កាលពីមុនបាននិយាយថា គាត់បានឃើញស្ត្រីមានផ្ទៃពោះជាប់ឃុំនៅក្នុងមន្ទីរស-២១ ផ្ទុយទៅវិញនៅថ្ងៃនេះ ប្រាក់ ខន បានអះអាងខុសពីសក្ខីកម្មដើម ។ បន្ថែមលើការកត់សម្គាល់នៃភាពផ្ទុយគ្នានេះ លោកចៅក្រម ឡាវីញ បានបង្ហាញថា ប្រាក់ ខន បានប្រាប់ចៅក្រមស៊ើបអង្កេតថា ឌុច ពេលខ្លះមានវត្តមាននៅក្នុងពេលសួរចម្លើយ ដោយឡែកថ្ងៃនេះ ប្រាក់ ខន បានប្រាប់អង្គជំនុំជម្រះសាលាដំបូងថា ឌុច មិនដែលធ្លាប់មានវត្តមានក្នុងពេលសួរចម្លើយទៅវិញ ។ សក្ខីកម្មដ៏មានផលប៉ះពាល់ខ្លាំងបំផុតដល់ការកាត់ទោសនេះហាក់បីដូចជាបានកើតឡើងខណៈពេលដែលអ្នកស្រីចៅក្រម ខាត់វ៉្រាយ បានសួរថាតើសាក្សីបានចង់ចាំច្បាស់លាស់នូវសក្ខីកម្មដែលខ្លួនបានផ្ដល់ឲ្យដែរឬទេ ឬសាក្សីពេលខ្លះអាស្រ័យលើអ្វីដែលមនុស្សបានប្រាប់គាត់កាលពីពេលថ្មីនេះ ។ សាក្សីបានឆ្លើយថា “ពិតជាអ៊ីចឹងមែន” ។ ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានវិធានតឹងរឹងប្រឆាំងនឹងពាក្យចចាមអារាម ដូចជាការផ្ដល់ចម្លើយបែបនេះ ហើយបើពិចារណាទៅលើភាពផ្ទុយគ្នាវិញ សក្ខីកម្មរបស់សាក្សីទាំងស្រុងហាក់បីដូចជាមិនសូវមានភាពជឿជាក់ប៉ុន្មានទេ ។